ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ: ៤០៤៤ មស.ក្រ

## សូមគោរពជូន
## សម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន

**កម្មវត្ថុ ៖** ស្ដីពីការផ្ដល់ផែនការក្របខណ្ឌជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៨។

**យោង ៖** - ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

- របាយការណ៍ស្ដីពីផែនការក្របខណ្ឌឆ្នាំ២០១៨ របស់ក្រសួង ស្ថាប័ន។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន សម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា រាជរដ្ឋាភិបាល បានយល់ព្រមផ្ដល់ជាគោលការណ៍ជ្រើសរើសក្របខណ្ឌថ្មីមន្ត្រីរាជការស៊ីវិលចំនួន ៥.០២៩កន្លែង មន្ត្រីជាប់កិច្ចសន្យាចំនួន ១៨.១៤៦នាក់ គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះដឹងទូទៅចំនួន ៦.៥៨៥នាក់ គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធចំនួន ២.៤៧២នាក់ គ្រូបង្រៀនពីរថ្នាក់ ពីរពេលចំនួន ១៣.៣៣១នាក់ និងគ្រូបង្រៀនថ្នាក់គួបគ្រប់កម្រិតចំនួន ២.៩៣៥នាក់ ដើម្បីផ្ដល់ជូនគ្រប់ក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងមន្ទីរ អង្គភាពជំនាញ រាជធានី ខេត្ត សម្រាប់ឆ្នាំ២០១៨ ដូចមានបែងចែកតាមចំនួនដូចខាងក្រោម៖

| ល.រ | ក្រសួង ស្ថាប័ន | ក្របខណ្ឌធនធានមនុស្សផ្ដល់ជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៨ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ក្របខណ្ឌថ្មី | មន្ត្រីជាប់កិច្ចសន្យា | គ្រូបង្រៀនជាប់កិច្ចសន្យា | គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះដឹងទូទៅ | គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ | គ្រូបង្រៀនពីរថ្នាក់ ពីរពេល | គ្រូបង្រៀនថ្នាក់គួបគ្រប់កម្រិត |
| ១ | ព្រះបរមរាជវាំង | ០០ | ២៥០ | | | | | |
| ២ | ទីស្ដីការគណៈរដ្ឋមន្ត្រី | ១៦ | ១១២ | | | | | |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ២០ | ៥២ | | | | | |
| ៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ០០ | ១៤៣ | | | | | |
| ៥ | មហាផ្ទៃ | ៣៩៣ | ១៣៨៤ | | | | | |
| ៦ | ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច | ០០ | ២៥០ | | | | | |
| ៧ | ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១៥ | ១០០ | | | | | |
| ៨ | សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០០ | ៤៧៥ | | | | | |



ផ្លូវវិថីរូអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

| ល.រ | ក្រសួង ស្ថាប័ន | ក្របខណ្ឌធនធានមនុស្សផ្តល់ជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៨ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ក្របខណ្ឌ | មន្ត្រីជាប់កិច្ចសន្យា | គ្រូបង្រៀនពុទ្ធិក ជាប់កិច្ចសន្យា | គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះដឹងទូទៅ | គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ | គ្រូបង្រៀនពីរថ្នាក់ ពីរពេល | គ្រូបង្រៀនថ្នាក់គួប គ្រប់កម្រិត |
| ៩ | ព័ត៌មាន | ០០ | ៧១៥ | | | | | |
| ១០ | សុខាភិបាល | ៧០០ | ៣៥៦៨ | | | | | |
| ១១ | រ៉ែ និងថាមពល | ១១ | ២០០ | | | | | |
| ១២ | ផែនការ | ០០ | ១២៥ | | | | | |
| ១៣ | ពាណិជ្ជកម្ម | ២០ | ២០១ | | | | | |
| ១៤ | អប់រំ យុវជន និងកីឡា | ៣៦០០ | ៥៤១ | | ៦៥៨៥ | ២៤៧២ | ១៣៣៣១ | ២៩៣៨ |
| ១៥ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៤០ | ១០២៤ | | | | | |
| ១៦ | វប្បធម៌និងវិចិត្រសិល្បៈ | ៣០ | ៤០៩ | | | | | |
| ១៧ | បរិស្ថាន | ១៨ | ៣៥៥ | | | | | |
| ១៨ | អភិវឌ្ឍន៍ជនបទ | ២០ | ៤៧ | | | | | |
| ១៩ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០០ | ៦២៧ | | | | | |
| ២០ | ប្រៃសណីយ៍និងទូរគមនាគមន៍ | ២០ | ១២៦ | | | | | |
| ២១ | ធម្មការ និងសាសនា | ០០ | ៥១៦ | | | | | |
| ២១.១ | អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ | ០០ | ០០ | ១៤៦២ | | | | |
| ២២ | កិច្ចការនារី | ២០ | ៤១០ | | | | | |
| ២៣ | សាធារណការ និងដឹកជញ្ជូន | ៥០ | ១៥៥០ | | | | | |
| ២៤ | យុត្តិធម៌ | ០១ | ៦២ | | | | | |
| ២៤.១ | អគ្គនាយកដ្ឋានកិច្ចការតុលាការ | ០០ | ៤៧០ | | | | | |
| ២៥ | ទេសចរណ៍ | ១៥ | ៥២៩ | | | | | |
| ២៦ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០ | ៣២៣ | | | | | |
| ២៧ | ធនធានទឹក និងឧតុនិយម | ២០ | ៤៤៥ | | | | | |
| ២៧.១ | គណៈកម្មការជាតិទន្លេមេគង្គកម្ពុជា | | ១៥ | | | | | |
| ២៧.២ | អាជ្ញាធរទន្លេសាប | | ២៩ | | | | | |
| ២៨ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៤ | ៣៨៨ | | | | | |
| ២៩ | អង្គភាពប្រឆាំងអំពើពុករលួយ | ០១ | ១៩០ | | | | | |
| ៣០ | មុខងារសាធារណៈ | ០៥ | ២៩៨ | | | | | |
| ៣១ | ឧស្សាហកម្មនិងសិប្បកម្ម | ២០ | ២០០ | | | | | |
| ៣២ | គណៈកម្មាធិការជាតិប្រឆាំងអំពើការវកម្ម | ០០ | ៧៨ | | | | | |
| | សរុប | ៥.០២៩ | ១៦.៦៨៤ | ១.៤៦២ | ៦.៥៨៥ | ២.៤៧២ | ១៣.៣៣១ | ២.៩៣៨ |

យោងតាមចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដូចមានយោងខាងលើ ក្រសួងមុខងារសាធារណៈ សូមគោរពស្នើគ្រប់ក្រសួង ស្ថាប័ន មេត្តាសហការអនុវត្តនូវគោលការណ៍មួយចំនួនដូចខាងក្រោម៖

**១. វិធានការចំពោះការជ្រើសរើសនិងការប្រើប្រាស់ធនធានមនុស្សឆ្នាំ២០១៨**

**១.១ ការជ្រើសរើសដោយការប្រឡងប្រជែងផ្ទៃក្នុងពីចំណោមមន្ត្រីរាជការក្នុងក្រសួង ស្ថាប័នសាមី**

គ្រប់ក្រសួង ស្ថាប័នដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី ត្រូវរៀបចំឱ្យមានការប្រឡងប្រជែងផ្ទៃក្នុងក្រសួង ស្ថាប័នសាមីនីមួយៗជាមុន ដោយជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់ក្នុងក្រសួង ស្ថាប័នសាមី ដើម្បីបំពេញមុខតំណែងដែលត្រូវជ្រើសរើស ទើបអាចធ្វើការប្រឡងប្រជែងជ្រើសរើសពីក្នុងចំណោមសិស្ស និស្សិតនិងមន្ត្រីរាជការទូទៅបាន។ ការអនុវត្តន៍បែបនេះនឹងផ្តល់ឱកាសដល់មន្ត្រីរាជការអាចផ្លាស់ប្តូរអាជីពការងារក្នុងក្រសួង ស្ថាប័នតែមួយ ការពង្រាយមន្ត្រីពីកន្លែងលើសមន្ត្រី ទៅកន្លែងខ្វះមន្ត្រី ព្រមទាំងអាចកាត់បន្ថយចំណាយមួយចំនួនថែមទៀត។ ការប្រឡងប្រជែងផ្ទៃក្នុងពីចំណោមមន្ត្រីរាជការក្នុងក្រសួង ស្ថាប័នសាមី និងប្រកាសលទ្ធផលជាប់ជាស្ថាពរយ៉ាងយូរត្រឹមបំណាច់ខែមីនា ឆ្នាំ២០១៨។

**១.២ ការជ្រើសរើសដោយការប្រឡងប្រជែងពីក្នុងចំណោមសិស្ស និស្សិត និងមន្ត្រីរាជការទូទៅ**

បន្ទាប់ពីការប្រឡងប្រជែងផ្ទៃក្នុងពីចំណោមមន្ត្រីរាជការ ក្រសួង ស្ថាប័នត្រូវពិនិត្យឡើងវិញមុខតំណែងទំនេរដែលត្រូវជ្រើសរើស និងត្រូវធ្វើការប្រកាសជ្រើសរើសចេញពីការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត និងមន្ត្រីរាជការទូទៅ និងត្រូវប្រឡងក្រោយកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ និងប្រកាសលទ្ធផលជាប់ស្ថាពរយ៉ាងយូរត្រឹមដំណាច់ខែតុលា ឆ្នាំ២០១៨ ព្រមទាំងចាត់ចែងរៀបចំបើកផ្តល់បៀវត្សដល់បេក្ខជនប្រឡងជាប់ឱ្យបានរួចរាល់យ៉ាងយូរ ០១ខែក្រោយការប្រកាសលទ្ធផល។ ក្នុងករណីខកខានមិនបានរៀបចំការប្រឡងប្រជែងតាមកាលកំណត់ ត្រូវចាត់ទុកថាក្រសួង ស្ថាប័ន មិនមានតម្រូវការជ្រើសរើស និងមិនត្រូវអនុញ្ញាឱ្យធ្វើការជ្រើសរើសមន្ត្រីក្របខណ្ឌ ពីក្នុងចំណោម សិស្ស និស្សិត និងមន្ត្រីរាជការទូទៅក្នុងឆ្នាំ២០១៨ ឡើយ។

**១.៣ ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីជាប់កិច្ចសន្យាប្រភេទផ្សេងទៀត**

ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីជាប់កិច្ចសន្យាប្រភេទផ្សេងទៀតដែលត្រូវបានអនុញ្ញាតជាគោលការណ៍ដោយរាជរដ្ឋាភិបាល ត្រូវអនុវត្តតាមលក្ខខណ្ឌ បែបបទ និងនីតិវិធីជាធរមាន។

**២. វិធានការចំពោះការជ្រើសរើសនិងការប្រើប្រាស់ធនធានមនុស្សឆ្នាំ២០១៨**

ជាគោលការណ៍ ក្រសួង ស្ថាប័នត្រូវពង្រឹងការប្រើប្រាស់ធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់ស្របជាមួយនឹងគោលនយោបាយបង្កើនបៀវត្សរបស់រាជរដ្ឋាភិបាល។ ទោះជាយ៉ាងណា ក្នុងករណីដែលក្រសួង ស្ថាប័ន មានតម្រូវការចាំបាច់ប្រើប្រាស់ធនធានមនុស្សលើសពីគោលការណ៍អនុញ្ញាតរបស់រាជរដ្ឋាភិបាល សំណើនេះត្រូវឆ្លងកាត់នីតិវិធី៖

- ក្រសួង ស្ថាប័ន ត្រូវធ្វើការវិភាគមុខងារ រចនាសម្ព័ន្ធ ការពិពណ៌នាមុខតំណែងក្នុងក្រសួង ស្ថាប័នសាមីជាមុនដើម្បីធានានូវប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានមនុស្ស
- ត្រូវមានការពិគ្រោះយោបល់ផ្នែកបច្ចេកទេស និងផ្នែកលទ្ធភាពថវិកាជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីស្នើសុំការពិនិត្យ និងសម្រេចពីរាជរដ្ឋាភិបាល
- ការជ្រើសរើសត្រូវប្រកាសផ្សព្វផ្សាយ និងប្រឡងប្រជែងជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការនៅក្រសួង ស្ថាប័នដែលលើសមន្ត្រីរាជការជាមុន
- ក្រសួង ស្ថាប័ន ដែលអនុញ្ញាតឱ្យមន្ត្រីរាជការចូលរួមប្រឡងនិង/ឬចេញទៅបម្រើការងារនៅក្រសួង ស្ថាប័នដែលមានតម្រូវការជ្រើសរើស មិនត្រូវបានអនុញ្ញាតឱ្យធ្វើការជ្រើសរើសមន្ត្រីថ្មី ទៅបំពេញជំនួសមុខតំណែងនោះឡើយ

- ក្នុងករណី ការប្រឡងជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការមិនបានសម្រេច រាជរដ្ឋាភិបាលអនុញ្ញាតឱ្យមានការបើកការប្រឡងប្រជែងពីក្នុងចំណោមសិស្ស និស្សិត និងមន្ត្រីរាជការទូទៅបាន។ ប្រសិនបើពុំមានការរៀបចំការប្រឡងប្រជែងតាមកាលកំណត់ ត្រូវបានចាត់ទុកថាក្រសួង ស្ថាប័ន មិនមានតម្រូវការជ្រើសរើសឡើយ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា នៅពេលបើកឱ្យមានការប្រឡងប្រជែងសូមមេត្តា រៀបចំជ្រើសរើសបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឱ្យចូលបម្រើការងារ ដើម្បីបំពេញមុខតំណែងដែលទំនេរ និងសេចក្តីត្រូវការដែលមានពិតប្រាកដនៅតាមអង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងមន្ទីរអង្គភាពជំនាញ រាជធានី ខេត្ត ព្រមទាំងយកចិត្តទុកដាក់ដល់បេក្ខភាពជាជនពិការដែលមានសមត្ថភាពសមស្រប ២% នៃចំនួនក្របខណ្ឌសរុបរបស់ សាមីក្រសួង ស្ថាប័ន ហើយត្រូវមានបេក្ខនារីជាប់ជាស្ថាពរពី ២០% ទៅ ៥០% នៃចំនួនក្របខណ្ឌដែលទទួលបានប្រចាំឆ្នាំ។

សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តារៀបចំស្នើសុំមន្ត្រីតំណាងក្រសួងមុខងារសាធារណៈ ចូលរួមក្នុងដំណើការប្រឡងឱ្យបានមុនពេលរៀបចំបង្កើតគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសប្រចាំឆ្នាំ ដើម្បីក្រសួងមុខងារសាធារណៈមានលទ្ធភាពចូលរួមសហការចាប់តាំងពីដំណាក់កាលដំបូង។

សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិនា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

" ដើម្បីជូនជ្រាប "

-នាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌនៃក្រសួងមុខងារសាធារណៈ

-មន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត

-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត

" ដើម្បីសហការអនុវត្ត "

-ឯកសារ កាលប្បវត្តិ